ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តថេរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន

នៅក្នុងសាលដីកានាថ្ងៃនេះ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងបដិសេធសំណើសុំដោះលែងនៅក្រៅឃុំ។ អនុលោមតាមសាលដីការបស់អង្គបុរេជំនុំជម្រះ អៀង សារី អាចត្រូវស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។

អៀង សារី ដែលបានកាន់តួនាទីជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម (សំណុំរឿងនេះគឺកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត)។ អៀង សារី ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួនបណ្តោះអាសន្នជាលើកដំបូងរយៈពេលមួយឆ្នាំកាលពីថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ២០០៧។ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរយៈពេលជាអតិបរមាចំនួនមួយឆ្នាំទៀត(រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩)។

នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នអង្គបុរេជំនុំជម្រះបានយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្ននៅតែមានភាពចាំបាច់ក្នុងការការពារកុំអោយជនត្រូវចោទរត់គេចខ្លួន។ លើសពីនេះទៅទៀតអង្គបុរេជំនុំជម្រះយល់ថាការបន្តឃុំខ្លួនបណ្តោះអាសន្នមានលក្ខណចាំបាច់ដើម្បីធានាថាជនជាប់ចោទមានវត្តមានរាល់ពេលបើកសវនាការសាធារណៈនិងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

ការសម្រេចចិត្តដោយសង្ខេបនេះត្រូវបានអានដោយឯកឧត្តម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះនៅក្នុងសវនាការជាសាធារណៈនាថ្ងៃនេះ។ សាលដីកាជាលាយលក្ខអក្សរលំអិតអាចស្វែងរកបានក្នុងគេហទំព័រ៖
http://www.eccc.gov.kh/khmer/cabinet/courtDoc/317/C22_5_39_KH.pdf

រូបថតជាផ្លូវការស្ដីពីសវនាការនាថ្ងៃនេះក៏មាននៅក្នុងគេហទំព័រផងដែរ
http://www.eccc.gov.kh/english/cabinet/photo/40/01ISary26June09.jpg
http://www.eccc.gov.kh/english/cabinet/photo/40/02ISary26June09.jpg
http://www.eccc.gov.kh/english/cabinet/photo/40/03ISary26June09.jpg
http://www.eccc.gov.kh/english/cabinet/photo/40/04ISary26June09.jpg

សម្រាប់រូបថតទាំងនេះ អ្នកសារព័ត៌មានទាំងអស់អាចប្រើប្រាស់បានតាមសេចក្ដីត្រូវការ ប៉ុន្ដែគួរតែបញ្ជាក់ថារូបថតទាំងនេះផ្ដល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក ឡាស អូលសិន
មន្ត្រីទទួលបន្ទុកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័ត: +855 (0) 12 488 023
ទូរស័ព្ទ: +855 (0) 23 219 814 លេខបន្ត6169
សារអេឡិចត្រូនិច: olsenl@un.org

លោក រាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័ត: +855-12 488 156
ទូរសារ: +855-23 219 841
សារអេឡិចត្រូនិច: reach.sambath@eccc.gov.kh

លោកឌីម សុវណ្ណរ៉ុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
សារអេឡិចត្រូនិច
dim.sovannarom@eccc.gov.kh